# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

លេខ ៣១០ "ខ១"

ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ: ១១០៩

ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧

**សំណុំរឿងស៊ើបសួរ**

លេខ: ១១៩

ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨

**ជំនុំជម្រះ**

លេខ: ៤០៨០

ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨

**តាមនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈនា ថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០

វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក នាសាលសវនាការទី៥ ជាន់ទី១

ដោយមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១១០៩ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ ដែលមាន៖**

**ជនជាប់ចោទ** ឈ្មោះ [redacted]**មរកត** ភេទស្រី អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ មុខរបរពាណិជ្ជករ ទីកន្លែងកំណើតសង្កាត់ [redacted] ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ននៅ [redacted] ធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម៉ារ៉េត "រស់" ម្តាយឈ្មោះ [redacted] សុផានី "រស់" ប្តីឈ្មោះ [redacted] ប៊ុននាង "រស់" មានកូន០២នាក់ ទោសពីមុនគ្មាន ជានីតិជន ។ ( ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ លេខ ៥០៥៦ "ជ" ដ.ព.ស ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨ )

មានមេធាវីការពារសិទ្ធិលោក [redacted] ជាមេធាវីនៃក្រុមមេធាវីកម្ពុជាអន្តរជាតិ ដែលមានអាសយដ្ឋាននៅអគារIOC ជាន់ទី៥ បន្ទប់ $F_5$-R01 & $F_5$-R02 មហាវិថីព្រះមុនីវង្ស សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

មានមេធាវីការពារសិទ្ធិលោក [redacted] ជាមេធាវីនៃក្រុមមេធាវីជេស៊ី ដែលមានអាសយដ្ឋាននៅអគារផ្សារទំនើបបាយ័ន (ជិតទីស្តីការនាយករដ្ឋមន្ត្រី) ជាន់**ទី៤** បន្ទប់ $F_4$-402A ផ្លូវលេខ១១៤ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

ជាប់ចោទពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅខេត្តសៀមរាប ចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌមានចែង និង ឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

**ដើមបណ្តឹងរដ្ឋប្បវេណី** ឈ្មោះ [redacted] **ចំរើន** ភេទប្រុស អាយុ៥២ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះលេខ១៦៨០ ផ្លូវជាតិលេខ៥ ភូមិ៦១ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

មានមេធាវីការពារសិទ្ធិលោក [redacted] ការិយាល័យអគារលេខ ៣៥CD ផ្លូវលេខ២៧១ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

មានមេធាវីការពារសិទ្ធិលោកស្រី [redacted] ជាសមាជិកមេធាវីនៃក្រុមមេធាវី ខ្មែរ អប្សរា ដែលមានអាសយដ្ឋាននៅផ្ទះលេខ៥A ផ្លូវលេខ២៨៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

មានមេធាវីការពារសិទ្ធិលោកស្រី [redacted] ជាមេធាវីនៃក្រុមមេធាវី អឹម អេស អិន ដែលមានការិយាល័យផ្ទះលេខ ៣៦$E_0$ ផ្លូវ៩៩ ភូមិ៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៩ ឈ្មោះ [redacted] មរកត និងឈ្មោះ [redacted] ចំរើន បានចូលហ៊ុនធ្វើអាជីវកម្មចាស់លើសណ្ឋាគារ New Siem Reap Town Hotel និងពង្រីកអាជីវកម្មបន្ថែមបើកសណ្ឋាគារ New Angkor Land ជាមួយគ្នាដោយឯកភាព 50% ម្នាក់លើចំណូល និងចំណេញ ។ នៅពេលធ្វើអាជីវកម្មសណ្ឋាគារទាំងពីរ ឈ្មោះ [redacted] មរកត និងឈ្មោះ [redacted] ចំរើន បានរួមគ្នាខ្ចីប្រាក់ពីធនាគារ អានកូ បួនដង សរុប ២១០.០០០ (ម្ភៃមួយម៉ឺន) ដុល្លារអាមេរិក ។ ក្រោយមកដោយមានបញ្ហាខ្វះខាតក្នុងអាជីវកម្មក៏សម្រេចចិត្តខ្ចីប្រាក់រួមគ្នាជាបន្តបន្ទាប់ពីធនាគារ អេ ប៊ី អេ ABA ចំនួន ៨០.០០០ ( ប្រាំបីម៉ឺន) ដុល្លារអាមេរិក , ធនាគារ សូណាត្រា (SONATRA) ចំនួន ២០.០០០ ( ពីរម៉ឺន) ដុល្លារអាមេរិក និង ធនាគារ ស៊ី អា អឹម ប៊ី ( CIMB ) ចំនួន ១៣០.០០០ ( ដប់បីម៉ឺន ) ដុល្លារអាមេរិក ហើយព្រមព្រៀងរួមគ្នាសងការប្រាក់ទៅធនាគារ ដោយប្រើប្រាស់ប្រាក់ចំណូលដែលបានមកពីអាជីវកម្ម ។ រាល់ការខ្ចីប្រាក់រួមគ្នាឈ្មោះ [redacted] មរកត មិនដែលមានដាក់ទ្រព្យធានាទេ គឺមានតែឈ្មោះ [redacted] ចំរើន យកទ្រព្យផ្ទាល់ខ្លួនទៅដាក់ធានា ។ ក្រោយមកអាជីវកម្មចេះតែជួបវិបត្តិហិរញ្ញវត្ថុជាញឹកញាប់ និងខ្វះប្រាក់បង់ការឱ្យធនាគារ ទើបឈ្មោះ [redacted] ចំរើន ស្វែងរកមូលហេតុឃើញថា ឈ្មោះ [redacted] មរកត បានយកប្រាក់ចំណូលដែល បានមកពីអាជីវកម្មរួមគ្នានោះ ទៅបម្រើផលប្រយោជន៍ផ្ទាល់ខ្លួនដោយយកទៅទិញខុនដូ ទិញរថយន្តឱ្យម្តាយ និងបងប្រុស ។ ផ្ទេរប្រាក់ទាំងនោះឱ្យទៅបុគ្គលដទៃដែលមិនពាក់ព័ន្ធនឹងអាជីវកម្មតាមរយៈគណនីលេខ ៨៤៣១៥៥ របស់ធនាគារ ANZ ROYAL ទៀតផង ។ លើសពីនេះ ឈ្មោះ [redacted] មរកត បានយកប្រាក់លក់ហ៊ុន នៃភោជនីយដ្ឋានមរកត ស្ពាននាគ ដាក់ចូលគណនី ផ្ទាល់ខ្លួនទៅវិញ ជាហេតុធ្វើឱ្យអាជីវកម្មរួមគ្នានោះខាតបង់យ៉ាងធ្ងន់ធ្ងរ ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ៤០៧៦ អ.យ.ខ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨

**-បានឃើញ** ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៥១៥ “ផ” ដ.ដ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨

## នាពេលសវនាការ

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ចំរើន** បានឆ្លើយថា៖ កាលពីអំឡុងខែសីហា ឆ្នាំ២០០៨ ខ្លួនព្រមជាមួយសមាជិកភាគហ៊ុនចំនួន៤នាក់ទៀតមានឈ្មោះ [redacted] MYUNG , ឈ្មោះ [redacted] ចាន់ផា ឈ្មោះ [redacted] ប៊ុណ្ណា និងឈ្មោះ [redacted] មរកត បានចូលហ៊ុនគ្នាធ្វើអាជីវកម្មលើសណ្ឋាគារមួយឈ្មោះថា NEW SIEM REAP TOWN HOTEL ។ លុះដល់ឆ្នាំ២០០៩ ដោយសារតែមានវិបត្តិសេដ្ឋកិច្ចកើតឡើង ឈ្មោះ [redacted] MYUNG , ឈ្មោះ [redacted] ចាន់ផា ឈ្មោះ [redacted] ប៊ុណ្ណា មិនមានលទ្ធភាពក្នុងការបន្តអាជីវកម្មនេះ ទើបធ្វើការលះបង់ការខាតបង់នូវប្រាក់ភាគហ៊ុនដែលចូលរួមកណ្តាលទី ។ បន្ទាប់មក ឈ្មោះ [redacted] មរកត ក៏ហៅខ្លួនឱ្យចូលហ៊ុនបន្តលើអាជីវកម្មចាស់ នៃសណ្ឋាគារ NEW SIEM REAP TOWN HOTEL ។ នៅពេលបន្តអាជីវកម្មចាស់នេះ ខ្លួនបានដាក់ភាគហ៊ុនគិតជាប្រាក់ចំនួន USD ៣០.០០០ បន្ថែមលើអាវីជកម្មចាស់នោះ ។ ក្រោយមកខ្លួន និងឈ្មោះ [redacted] មរកត បានសម្រេចពង្រីកអាជីវកម្មបន្ថែមលើសណ្ឋាគារ New Angkor

Land ដោយឯកភាព ៥០% ម្នាក់ លើចំណូល ចំណាយ និង ចំនេញ ដោយមានកិច្ចសន្យាចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៩ ។ នៅពេលចាប់ផ្តើមធ្វើអាជីវកម្មសណ្ឋាគារទាំងពីរ ខ្លួន និងឈ្មោះ [redacted] មរកត បានរួមគ្នាខ្ចីប្រាក់ពីធនាគារអានក្លូ លើកទី១ ចំនួន USD ៨០.០០០ លើកទី២ ចំនួន USD ៦០.០០០ លើកទី៣ ចំនួន ៤០.០០០ និងលើកទី៤ ចំនួន USD ៣០.០០០ សរុប USD ២១០.០០០ ។ ក្រោយមកអាជីវកម្មត្រូវការដើមទុនបន្ថែមទៀត ខ្លួន និងឈ្មោះ [redacted] មរកត បាន សម្រេចចិត្តខ្ចីប្រាក់ពីធនាគារABA ចំនួន USD ៨០.០០០ ធនាគារសូណាត្រា ចំនួន USD ២០.០០០ និងធនាគារ ស៊ី អាយ អឹម ប៊ី (CIMB) ចំនួន USD ១៣០.០០០ ។ រាល់ការខ្ចីប្រាក់ទាំងអស់ គឺសម្រាប់មកធ្វើអាជីវកម្មរួមរវាងខ្លួន និងឈ្មោះ ពូន មរកត ។ ចំពោះអចលនវត្ថុសំរាប់ដាក់ធានាបំណុលទាំងអស់ គឺជាអចលនវត្ថុរបស់ខ្លួនតែម្នាក់ប៉ុណ្ណោះ ឈ្មោះ [redacted] មរកត មិនបានដាក់ទ្រព្យអ្វីសំរាប់ធានាទេ ប៉ុន្តែទទួលស្គាល់ប្រាក់បំណុលព្រោះមានផ្តិតមេដៃលើឯកសារកម្ចី ។ ដំបូងក្រុមហ៊ុនមិនមានគណនីទេ ការដាក់ប្រាក់ ផ្ទេរប្រាក់ គឺដាក់ចូលគណនីរបស់ឈ្មោះ [redacted] មរកត នៅពេលក្រុមហ៊ុនមានគណនី ទើបប្រើគណនីក្រុមហ៊ុនវិញដែលមានពីរ ប៉ុន្តែមិនបានកំណត់ថាចំណូលពីក្រុមហ៊ុនណាបញ្ចូលក្នុងគណនីមួយណាទេ។ ខ្លួនសង្កេតឃើញថា ក្រុមហ៊ុនជួបវិបត្តិហិរញ្ញវត្ថុជាញឹកញាប់ ហើយរាល់ការចុះហត្ថលេខាលើឯកសារចំណាយទាំងអស់គឺឈ្មោះ [redacted] មរកត ជាអ្នកចុះហត្ថលេខា ប៉ុន្តែឈ្មោះ [redacted] មរកត មិនបានយកប្រាក់ទាំងនោះចំណាយក្នុងអាជីវកម្មទេ គឺប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួនដូចជាទិញខុនដូ និងផ្ទេរប្រាក់ទៅគណនីផ្ទាល់ខ្លួនដោយប្រាប់ថាខ្ចីប្រាក់ក្រុមហ៊ុនសិន ប៉ុន្តែពុំបានផ្ទេរត្រឡប់មកក្រុមហ៊ុនវិញទេ ។ តាំងពីដាក់ហ៊ុនជាមួយគ្នាមិនដែលបានចែកចំណេញទេ ព្រោះលុយចំណេញយកពង្រីកអាជីវកម្មបន្ថែម ។ នៅពេលភាគហ៊ុននៃភោជនីយដ្ឋានមរកតស្ពាននាគ ដែលជាការចូលហ៊ុនគ្នាក្នុងការធ្វើអាជីវកម្មលក់បានពីរហ៊ុនក្នុងទឹកប្រាក់ USD ៤០.០០០ ហើយអ្នកទិញដាក់ចូលគណនីរបស់ឈ្មោះ [redacted] មរកត គឺពុំបានបែងចែកដល់បច្ចុប្បន្ន ។ ខ្លួនសូមទាមទារសំណងជម្ងឺចិត្តចំនួន USD ៥០.០០០ ។

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] **មរកត** នៅតំណាក់កាលចៅក្រមស៊ើបសួរបានឆ្លើយថា៖ ខ្លួនបានបើកអាជីវកម្មសណ្ឋាគារ និងភោជនីយដ្ឋានអង្គរណៃន មួយកន្លែងស្ថិតនៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ដោយបានជួលពីម្ចាស់ដើមឈ្មោះ [redacted] ម៉ាលី តាមរយៈកិច្ចសន្យា ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩ រយៈពេល ០៥ឆ្នាំ គិតចាប់ពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ ដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ។ បន្ទាប់មកក៏ជួលបន្តរយៈពេល ៥០ខែ គិតចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៥ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ។ ខ្លួនជាពាណិជ្ជករ មានជំនាញរកស៊ីទូទៅ មិនមាន ជំនាញផ្នែកគ្រប់គ្រងសណ្ឋាគារ-ភោជនីយដ្ឋាននោះទេ ។ ឈ្មោះ [redacted] ចំរើន មានជំនាញគ្រប់គ្រងសណ្ឋាគារ ខ្លួនក៏សម្រេចឱ្យចូលហ៊ុនរកស៊ីជាមួយគ្នា ដោយបង់ប្រាក់ USD ៣០.០០០ កំណត់ថាមានភាគហ៊ុន ៥០% ។ តាំងពីឈ្មោះ [redacted] ចំរើន គ្រប់គ្រងអាជីវកម្មអង្គរណៃន រហូតដល់បច្ចុប្បន្ន ពុំមានធ្វើរបាយការណ៍គ្រប់គ្រងអាជីវកម្មឡើយ ។ ឈ្មោះអ្នកទទួលខុសត្រូវ ឈ្មោះលើប៉ាតង់ ឈ្មោះបង់ពន្ធ ឈ្មោះក្នុងកិច្ចសន្យាជួលសណ្ឋាគារពីម្ចាស់ដើម និងការដោះស្រាយវិវាទ ពាក់ព័ន្ធនឹងសណ្ឋាគារអង្គរណៃន និងបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងអាជីវកម្មនេះពីឈ្មោះខ្លួន ហើយខ្លួនជាអ្នកដោះស្រាយពីដើមរហូតដល់ចប់ដោយឈ្មោះ [redacted] ចំរើន មិនដែលទទួលខុសត្រូវម្តងណានោះទេ ពីព្រោះឈ្មោះអាជីវកម្មគឺឈ្មោះខ្លួន ។ ហេតុនេះពន្ធដា ផាស៊ី សណ្ឋាគារ ជាដើម មករកខ្លួនឱ្យទទួលខុសត្រូវរហូត ។ ខ្លួនត្រូវប្រឈមមុខគ្រប់បែបយ៉ាងនៅពេលមានបណ្តឹងប្រឆាំងនឹងអាជីវកម្មអង្គរណៃន ដូចជាពីសំណាក់ម្ចាស់សណ្ឋាគារដើមឈ្មោះ [redacted] ម៉ាលី ពាក់ព័ន្ធនឹងការជួលសណ្ឋាគារ និងផ្តាច់កិច្ចសន្យាចំពោះថ្លៃឈ្នួលសព្វគ្រប់ដែលមិនទាន់បានបង់ដែលធ្វើឱ្យប៉ះពាល់ដល់អាជីវកម្ម មុខមាត់អាជីវកម្ម កិត្តិយសរបស់អាជីវកម្ម និងកិត្តិយសរបស់ខ្លួន បណ្តាលឱ្យអាជីវកម្មខាតទៅៗ ហើយខ្លួនត្រូវរ៉ាប់រងគ្រប់បែប



Scanned with CamScanner

យ៉ាងដោយឈ្មោះ [redacted] ចំរើន ឈរមើលមិនខ្វល់ហើយបែរមកប្ដឹងខ្លួនវិញ ។ ដំណើរការអាជីវកម្មសណ្ឋាគារអង្គរវ៉ែន ស្ថិតក្រោមការគ្រប់គ្រងទូទៅរបស់ឈ្មោះ [redacted] ចំរើន ហើយអាជីវកម្មនេះបន្តខាតជាប្រចាំ ដែលធ្វើឱ្យខ្លួនឆ្ងល់ និងចុះមកពិនិត្យដល់ទីតាំងប្រតិបត្តិការជាក់ស្តែងទើបដឹងថាឈ្មោះ [redacted] ចំរើន គ្រប់គ្រងមិនបានល្អ បញ្ជាចំណាយមិនត្រឹមត្រូវ ហេតុនេះ ក៏សម្រេចផ្លាស់ប្តូរអ្នកគ្រប់គ្រង ដោយខ្លួនអនុញ្ញាតឱ្យឈ្មោះ [redacted] ចំរើន ជ្រើសរើសអ្នកគ្រប់គ្រងថ្មី មកចាត់ចែងអាជីវកម្មនេះ ។ បន្ទាប់ពីជ្រើសរើសអ្នកគ្រប់គ្រងថ្មីបាន ២ ឬ ៣ ខែ ក៏បានបញ្ឈប់អ្នកគ្រប់គ្រងថ្មីនោះ ហើយឈ្មោះ ទេព ចំរើន ឡើងចាត់ចែងការងារនេះខ្លួនឯងម្តងទៀត ។ ការបន្តចាត់ចែងអាជីវកម្មនេះ នៅតែមិនល្អ ធ្វើឱ្យអាជីវកម្មនេះនៅតែបន្តខាត និងជំពាក់បំណុលកាន់តែច្រើនទៅៗ ។ ក្នុងស្ថានភាពនេះ ឈ្មោះ [redacted] ចំរើន បានស្នើចាកចេញពីអាជីវកម្មនេះ ដោយប្រាប់ខ្លួនឱ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងបញ្ចប់ការធ្វើអាជីវកម្មរួមគ្នា ។ ពេលនោះខ្លួនមិនយល់ព្រមទេ ដោយលើកឡើងថា បញ្ហាកំពុងកើតឡើង ត្រូវបន្តជួយគ្នា ហេតុអ្វីរត់ចោលពាក់កណ្តាលផ្លូវបែបនេះ ។ មួយរយៈក្រោយមកទៀត ឈ្មោះ [redacted] ចំរើន នៅតែចង់ឈប់រកស៊ីជាមួយគ្នា ដោយសុខចិត្តបង់ប្រាក់ចំនួន USD ៥០.០០០ មកខ្លួនដើម្បីបញ្ចប់អាជីវកម្មនេះ ឈ្មោះ [redacted] ចំរើន បង់បានUSD ២៨.០០០ ប៉ុណ្ណោះ ។ ចំពោះបំណុលកន្លងមក ផ្អែកតាមកិច្ចព្រមព្រៀងបញ្ចប់អាជីវកម្ម ភាគីទាំងពីរត្រូវទទួលខុសត្រូវរួមគ្នា គិតចាប់ពីផ្ដើមអាជីវកម្ម រហូតដល់មុនថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥។ គណនីរបស់អាជីវកម្មសណ្ឋាគារ និងភោជន័យដ្ឋានអង្គរវ៉ែន គឺជាគណនីរួមដោយប្រើឈ្មោះសណ្ឋាគារអង្គរវ៉ែន ដោយអ្នកមានសិទ្ធិបញ្ជាចំណាយគឺមានពីរនាក់ មានខ្លួន និងឈ្មោះ [redacted] ចំរើន ដោយប្រើលក្ខខណ្ឌបុគ្គលណាម្នាក់ក៏មានសិទ្ធិបើកប្រាក់ ឬ បញ្ជាចំណាយ ។ នៅក្នុងដំណើរការអាជីវកម្មសណ្ឋាគារអង្គរវ៉ែន គឺបានខ្ចីប្រាក់មួយចំនួនពីម្ចាស់បំណុល ហើយម្ចាស់បំណុលយល់ព្រមឱ្យខ្ចីដោយមើលឃើញអាជីវកម្មអង្គរវ៉ែន ហើយប្រាក់ចំណូលអាជីវកម្មនេះយកទៅសងរំលោះបំណុលសម្រាប់ម្ចាស់បំណុលជាដំណាក់កាលបន្តបន្ទាប់រហូតដាច់ឥណទានមួយ បន្ទាប់មកបន្តឥណទានមួយទៀត ។ ប៉ុន្តែនៅពេលខ្ចីប្រាក់ពីធនាគារ ដើម្បីគាំទ្រអាជីវកម្ម មិនដឹងថាឈ្មោះ [redacted] ចំរើន បានយកគាំទ្រអាជីវកម្មនេះទាំងមូល ឬបញ្ចូលមកគណនីអាជីវកម្មសណ្ឋាគារ ឬអត់នោះទេ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី

កាលពីអំឡុងឆ្នាំ២០០៨ កូនក្តីខ្លួនឈ្មោះ [redacted] **ចំរើន** ព្រមទាំងសមាជិក ៤ នាក់ទៀត ឈ្មោះ [redacted] **មរកត** ឈ្មោះ [redacted] **ចាន់ថា** ឈ្មោះ [redacted] **ប៊ុណ្ណា** និងឈ្មោះ [redacted] **MYUNG** បានចូលហ៊ុនគ្នាធ្វើអាជីវកម្មលើសណ្ឋាគារមួយឈ្មោះថា **NEW SIEM REAP TOWN HOTEL**។ ក្រោយមកក្នុងឆ្នាំ២០០៩ ការធ្វើអាជីវកម្មបានជួបវិបត្តិសេដ្ឋកិច្ច ម្ចាស់ភាគហ៊ុនឈ្មោះ [redacted] **ចាន់ថា** ឈ្មោះ [redacted] **ប៊ុណ្ណា** និងឈ្មោះ [redacted] **MYUNG** ក៏លះបង់ភាពជាម្ចាស់ហ៊ុនកណ្តាលទី ។ បន្ទាប់ពីម្ចាស់ហ៊ុនទាំងបីបានបញ្ចប់ការវិនិយោគហើយ ឈ្មោះ [redacted] **មរកត** ក៏បានបបួលកូនក្តីខ្លួនឱ្យដាក់ហ៊ុនបន្ថែមចំនួន USD ៣០,០០០ (បីម៉ឺនដុល្លារអាមេរិក) ដើម្បីពង្រីកអាជីវកម្មបន្ថែមបើកសណ្ឋាគារ និង ភោជនីយដ្ឋានអង្គរវ៉ែនដ៍ ដោយឯកភាពចូលហ៊ុនគ្នា ៥០% (ហាសិបភាគរយ) ម្នាក់ៗ ដូចមានកំណត់ក្នុងកិច្ចសន្យាចូលហ៊ុនធ្វើអាជីវកម្មបើកសណ្ឋាគារ និងភោជនីយដ្ឋានអង្គរវ៉ែនដ៍ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១០ ។ ក្រោយពីការបង្កើតសណ្ឋាគារ និងភោជនីយដ្ឋានអង្គរវ៉ែនដ៍ ឈ្មោះ [redacted] **ចំរើន** និង [redacted] **មរកត** បានរៀបចំរចនាសម្ព័ន្ធក្រុមហ៊ុនដោយឈ្មោះ [redacted] **មរកត** មានតួនាទីជានាយកគ្រប់គ្រង និងឈ្មោះ [redacted] **ចំរើន** មានតួនាទីជាអ្នកចាត់ការទូទៅតែប៉ុណ្ណោះ ។ នៅពេលធ្វើអាជីវកម្មជាមួយគ្នា ឈ្មោះ [redacted] **ចំរើន** និងឈ្មោះ [redacted] **មរកត** បានព្រមព្រៀងគ្នាខ្ចីប្រាក់ពីអ្នកចងការប្រាក់ឯកជន និងខ្ចីប្រាក់ពីធនាគារ និងព្រមព្រៀងយកប្រាក់ចំណូលពីអាជីវកម្មមកសងបំណុលទាំងនោះ ។ ចំពោះបំណុលដែលបានខ្ចីពីអ្នកចងការប្រាក់ឯកជន និងធនាគារព្រមទាំង



Scanned with CamScanner

ចំណាយលើសេវាធនាគារនានាសរុបចំនួន USD ៤២៧,០០០ (សែសិបម៉ឺនប្រាំពីពាន់ដុល្លារអាមេរិក) ដែលក្នុងនោះមានរួមមាន៖ កម្ចីពីអ្នកចងការប្រាក់ឯកជនសរុបចំនួន USD ១១៧.០០០ (ដប់ប្រាំពីរម៉ឺនដុល្លាអាមេរិក) កម្ចីពីធនាគារ អានក្រ ចំនួន៥លើក ដែលសរុបជាទឹកប្រាក់ចំនួន USD ១៨០.០០០ (ដប់ប្រាំបីម៉ឺនដុល្លារអាមេរិក) កម្ចីពីធនាគារ ស៊ីអឹមប៊ី (CIMB) ចំនួន USD ១៣០.០០០ (ដប់បីម៉ឺនដុល្លារអាមេរិក) ប៉ុន្តែក្រោយកូនក្តីខ្លួន និងឈ្មោះ [redacted] **មរកត** បានបញ្ចប់អាជីវកម្មជាមួយគ្នាតាមរយៈកិច្ចព្រមព្រៀងបញ្ចប់ការធ្វើអាជីវកម្មរួមគ្នា ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៦ បាននាំឱ្យមានការខកខានក្នុងការបង់ប្រាក់រំលោះដល់ធនាគារ រហូតដល់ថ្នាក់សុំធនាគារបង់ត្រឹមតែការប្រាក់ប៉ុណ្ណោះ ។ ក្រោយមក កូនក្តីខ្លួនក៏អស់សមត្ថភាពក្នុងការបង់រំលោះបន្តទៀត ហើយក៏បានផ្ទេរកម្ចីពីធនាគារ ស៊ី អាយ អឹម ប៊ី (CIMB) ទៅធនាគារ សុណាត្រា បន្ត ក្នុងចំនួនកម្ចីសរុបគឺ USD ១៣០,០០០ (ដប់បីម៉ឺនដុល្លារអាមេរិក) ដដែល ដូចភស្តុតាងដែលបានភ្ជាប់ជូន ។ ប៉ុន្តែបំណុលខាងលើនេះ បានទូទាត់មួយចំនួនក្នុងអំឡុងពេលធ្វើអាជីវកម្មជាមួយគ្នា ដូច្នេះគិតមកត្រឹមថ្ងៃដែលកូនក្តីខ្លួន និងឈ្មោះ [redacted] **មរកត** បានបញ្ចប់អាជីវកម្មជាមួយគ្នា បំណុលនៅសល់ USD ៤០៧.៤៧៨ (សែសិបម៉ឺនប្រាំពីរពាន់បួនរយចិតសិបប្រាំបីដុល្លារអាមេរិក) ។ ចំពោះប្រតិបត្តិការនៃការខ្ចីប្រាក់ខាងលើ កូនក្តីខ្លួនជាអ្នកដាក់ទ្រព្យផ្ទាល់ខ្លួន និងទ្រព្យរបស់បងប្អូនគាត់ធានាបំណុលទាំងអស់ ចំណែកកម្ចីពីអ្នកចងការប្រាក់ឯកជន ភាគច្រើនកូនក្តីខ្លួនចេញមុខខ្ចីតែម្នាក់ឯងលើសពីនេះទៅទៀត បំណុលដែលបានផ្ទេរតពីធនាគារ ស៊ី អាយ អឹម ប៊ី (CIMB) ទៅធនាគារ សុណាត្រា គឺដាក់តែឈ្មោះកូនក្តីខ្លួនម្នាក់តែប៉ុណ្ណោះ ដោយសារក្រោយបញ្ចប់អាជីវកម្មទៅ កូនក្តីខ្លួនមិនអាចរ៉ាប់រងបំណុលបានតែម្នាក់ឯង ស្របពេលដែលឈ្មោះ [redacted] **មរកត** មិនបានទទួលខុសត្រូវលើចំណែករបស់ខ្លួនទាល់តែសោះ ។ នៅក្នុងកំឡុងពេលធ្វើអាជីវកម្មរួមគ្នា កូនក្តីខ្លួនចាប់ផ្តើមឃើញថាការគ្រប់គ្រងប្រាក់ចំណូលចំណាយ មានភាពមិនប្រក្រតី ដោយសារឈ្មោះ [redacted] **មរកត** តែងតែស្នើសុំលុយចំណូលអាជីវកម្មពីកូនក្តីខ្លួនយកទៅប្រើប្រាស់ផ្ទាល់ខ្លួន ហើយមិនដែលបង្វិលត្រលប់ចូលប្រាក់ចំណូលអាជីវកម្មវិញទេ ដែលជាហេតុនាំឱ្យអាជីវកម្មនេះតែងជួបវិបត្តិហិរញ្ញវត្ថុជាញឹកញាប់ និងខ្វះប្រាក់បង់ការប្រាក់ធនាគារ ។ ដោយសារឃើញភាពមិនប្រក្រតីបែបនេះ កូនក្តីខ្លួនក៏សួរនាំពីបញ្ហានេះជាច្រើនដង ដែលធ្វើឱ្យឈ្មោះ [redacted] **មរកត** មិនសប្បាយចិត្ត និងមានបញ្ហាឈ្លោះប្រកែកគ្នាជារឿយៗ និងបានបោះពាក្យសំដីមកកូនក្តីខ្លួនថា រកស៊ីជាមួយគ្នា តើរកស៊ីជាមួយគ្នាដូចម្តេចទៅ ហេតុដូច្នេះហើយ កូនក្តីខ្លួនក៏ស្នើសុំបញ្ចប់អាជីវកម្មជាមួយឈ្មោះ [redacted] **មរកត** តាមរយៈកិច្ចព្រមព្រៀងបញ្ចប់ការធ្វើអាជីវកម្មរួមគ្នា ចុះថ្ងៃទី៧ ខែមករា ឆ្នាំ២០១៦ ដោយបែងចែកអាជីវកម្មសណ្ឋាគារទៅឈ្មោះ [redacted] **មរកត** និងភោជនីយដ្ឋានមរតកស្ពាននាគ មកកូនក្តីខ្លួន និងបែងចែកបំណុលរួមជាពីរ ប៉ុន្តែឈ្មោះ [redacted] **មរកត** បានដាក់លក្ខខណ្ឌឱ្យកូនក្តីខ្លួនបង់ប្រាក់ឱ្យចំនួន USD ៥០.០០០ (ប្រាំម៉ឺនដុល្លារអាមេរិក) ដើម្បីបញ្ចប់អាជីវកម្មជាមួយគ្នាទើបព្រមធ្វើបញ្ជីចំណូលចំណាយ និងទទួលស្គាល់បំណុលដែលមានមុនថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ ។ ប៉ុន្តែតាំងពីថ្ងៃនោះមកឈ្មោះ [redacted] **មរកត** មិនបានសងចំណែកបំណុលរបស់ខ្លួន ដូចខ្លួនបានអះអាងនោះទេ ។ ហេតុនេះ កូនក្តីខ្លួនក៏បានស្នើមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីស្រាវជ្រាវនូវប្រាក់ចំណូលរបស់អាជីវកម្ម និងពិនិត្យមើលលើរបាយការណ៍ធនាគារផ្ទាល់ខ្លួនរបស់ឈ្មោះ [redacted] **មរកត** ។ ក្រោយពីធ្វើការសើរើមកឃើញថា ឈ្មោះ [redacted] **មរកត** មិនត្រឹមតែយកប្រាក់ចំណូលពីអាជីវកម្មទៅប្រើប្រាស់ក្នុងរឿងផ្ទាល់ប៉ុណ្ណោះទេ ថែមទាំងកិបកេងប្រាក់ចំណូលរបស់អាជីវកម្ម ទៅគណនីធនាគារ អេ អិន ហ្សេត រ៉ូយ៉ាល់ (ANZ ROYAL) ដែលជាគណនីរួមរបស់ឈ្មោះ [redacted] **មរកត** និងឈ្មោះ [redacted] **ប៊ុននាង** ថែមទៀតផង ដែលរបាយការណ៍ធនាគារនេះ បានមកពីការស្នើសុំរបស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។ តាមរយៈរបាយការណ៍នេះឃើញថា ឈ្មោះ [redacted] **មរកត** បានកិបកេងប្រាក់អាជីវកម្មដោយធ្វើឡើងតាមរយៈការវេរ

ប្រាក់ជាពីររបៀប ទី១ គឺវេរចេញពីគណនីធនាគារឈ្មោះអង្គរឡែនដ៍ ដែលមានលេខគណនី ១៨០២៤៧០១ របស់ធនាគារអេអិនហ្សេត រ៉ូយ៉ាល់ (ANZ) និងគណនីធនាគារឈ្មោះ សៀមរាបថោន ដែលមានលេខគណនី ១២៣៣២៥២ របស់ធនាគារអេអិនហ្សេត រ៉ូយ៉ាល់ (ANZ) និងរបៀបទី២ គឺឈ្មោះ [redacted] **មរកត** បានប្រើបុគ្គលិកសណ្ឋាគារ ដែលភាគច្រើនជាសាច់ញាតិរបស់ឈ្មោះ [redacted] **មរកត** ឱ្យយកសាច់ប្រាក់សុទ្ធទៅដាក់ក្នុងគណនីផ្ទាល់ខ្លួនរបស់គាត់ ។ ជាទូទៅរាល់ពេលដែលបុគ្គលិកសណ្ឋាគារ យកប្រាក់សុទ្ធទៅដាក់ ឬវេរប្រាក់ចូលគណនីផ្ទាល់ខ្លួននោះ គឺឈ្មោះ [redacted] **ប៊ុនឆាង** ដែលជាអតីតប្តីរបស់ឈ្មោះ [redacted] **មរកត** ជាអ្នកដកប្រាក់យកទៅប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួនដូចមានចែងលំអិតក្នុងរបាយការណ៍ធនាគារ ANZ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ ។ សូមបញ្ជាក់ថា ការកែបំបាត់ប្រាក់ចំណូលដែលប្រព្រឹត្តដោយឈ្មោះ [redacted] **មរកត** ចាប់តាំងពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១០ រហូតដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ សរុបទាំងអស់មានចំនួន USD ២២៦.៥៨៦ (ម្ភៃពីរម៉ឺនប្រាំមួយពាន់ប្រាំរយប៉ែតសិបប្រាំមួយដុល្លារអាមេរិក) ស្របទៅតាមរបាយការណ៍ប្រតិបត្តិការលួចបន្លំសាច់ប្រាក់ និងតាមរយៈគណនីរបស់ក្រុមហ៊ុនចូលក្នុងគណនីលេខ ៨៨៣១៥៥ ដែលមានម្ចាស់គណនីរួមឈ្មោះ [redacted] **ប៊ុនឆាង** និងឈ្មោះ [redacted] **មរកត** ជាប្រព័ន្ធអ៊ិចសែលដែលមានភ្ជាប់ជូន ។ ក្រោយពីបានសួរដេញដោលក្នុងសវនាការ ឃើញឈ្មោះ [redacted] **មរកត** ពិតជាបានប្រព្រឹត្ត បទល្មើសរំលោភលើទំនុកចិត្ត ស្របតាមខ្លឹមសារនៃមាត្រា ៣៩១ និងផ្តន្ទាទោសដោយមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។ ដូចនេះ ខ្លួនសំណូមពរតុលាការ៖

-ផ្តន្ទាទោសទៅលើឈ្មោះ [redacted] **មរកត** ពីបទ**រំលោភទំនុកចិត្ត** និងចេញដីកាចាប់ខ្លួនឈ្មោះ [redacted] **មរកត** យកមកដាក់ទោស ទៅតាមនីតិវិធីច្បាប់ ។

-បង្គាប់ឱ្យឈ្មោះ [redacted] **មរកត** សងប្រាក់ចំនួន USD ២២៦.៥៨៦ (ម្ភៃពីរម៉ឺនប្រាំមួយពាន់ប្រាំរយប៉ែតសិបប្រាំមួយដុល្លារអាមេរិក) ដែលឈ្មោះ [redacted] **មរកត** បានលួចកែបន្លំ ។

-បង្គាប់ឱ្យឈ្មោះ [redacted] **មរកត** អនុវត្តកាតព្វកិច្ចលើចំណែកបំណុលរបស់ខ្លួនចំនួន USD ២០៣.៧៣៩ (ម្ភៃម៉ឺនបីពាន់ប្រាំពីររយសាមសិបប្រាំបួនដុល្លារអាមេរិក)ព្រមទាំងការប្រាក់ ២% នៃប្រាក់ដែលបានជំពាក់ធនាគារ ចាប់តាំងពីថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០១៥ រហូតមកដល់បច្ចុប្បន្ន ។

-ស្នើសុំអនុវត្តបណ្តោះអាសន្នលើចំណុច២ និង៣ ខាងលើ ។

-ទាមទារសំណង ខូចខាត និងជម្ងឺចិត្តចំនួន USD ៥០០,០០០ (ហាសិបម៉ឺនដុល្លារអាមេរិក) ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានសួរដេញដោលក្នុងសវនាការឃើញថា ឈ្មោះ [redacted] មរកត និងឈ្មោះ [redacted] ចំរើន ពិតជាបានចូលហ៊ុនគ្នាបើកសណ្ឋាគារនៅខេត្តសៀមរាប ។ ទោះបីឈ្មោះ [redacted] មរកត បដិសេធអង្គហេតុដែលដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងហើយតំណាងអយ្យការបានធ្វើការចោទប្រកាន់ក៏ដោយ តាមរបាយការណ៍ពីធនាគារ ANZ Royal ឃើញថា មានការផ្ទេរប្រាក់ពីគណនីសណ្ឋាគារទៅគណនីផ្ទាល់ខ្លួនរបស់ឈ្មោះ [redacted] មរកត ។ នេះបញ្ជាក់ថា មានភស្តុតាងគ្រប់គ្រាន់បង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] **មរកត** បានរំលោភលើទំនុកចិត្ត មែន ។ ហេតុដូចនេះ តំណាងអយ្យការប្តឹងសុំតុលាការឱ្យផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

កូនក្តីខ្លួនបានបើកអាជីវកម្មសណ្ឋាគារ និងភោជនីយដ្ឋានអង្គរឡែនដ៍ (Angkor Land Hotel) មួយកន្លែងស្ថិតនៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ដោយបានជួលពីម្ចាស់ដើមឈ្មោះ [redacted] ម៉ាលី តាមរយៈ



Scanned with CamScanner

កិច្ចសន្យាចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩ ។ ការជួលនេះ មានអំឡុងពេល ០៥ (ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ ដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ថ្លៃឈ្នួលប្រចាំខែ គឺ USD ៥.៥០០ ក្នុងមួយខែ ដោយម្ចាស់សណ្ឋាគារតម្រូវឱ្យកក់ចំនួន ០៧ ខែ ស្មើនឹង USD ៣៨.៥០០ ។ បន្ទាប់មក កូនក្តីខ្លួនក៏បន្តជួលសណ្ឋាគារនេះតាមរយៈកិច្ចសន្យាចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៥ ដែលមានខ្លឹមសារថា បន្តជួលរយៈពេល ៥០ (ហាសិប) ខែ គិតចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៥ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ។ កូនក្តីខ្លួនជាពាណិជ្ជករដែលមានជំនាញរកស៊ីទូទៅមិនមានជំនាញផ្នែកគ្រប់គ្រងសណ្ឋាគារភោជនីយដ្ឋាននោះទេ ហើយនៅពេលមានអ្នកបច្ចេកទេសជំនាញអាចរកស៊ីជាមួយបាន កូនក្តីខ្លួនក៏បានសម្រេចឱ្យចូលភាគហ៊ុន ។ នៅពេលនោះឈ្មោះ [redacted] ចំរើន ដែលជាអ្នកមានជំនាញគ្រប់គ្រងសណ្ឋាគារក៏បានចូលហ៊ុនរកស៊ីជាមួយដោយបានកំណត់ថា មានភាគហ៊ុន ៥០% (ហាសិបភាគរយ) ម្នាក់ ចំពោះអាជីវកម្មសណ្ឋាគារ និង ភោជនីយដ្ឋានអង្គរវ៉ែលនដ៍ ដូចមានកំណត់ក្នុងកិច្ចសន្យាចូលហ៊ុនធ្វើអាជីវកម្មបើកសណ្ឋាគារ និងភោជនីយកម្មអង្គរវ៉ែលនដ៍ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១០ ។ ទេព ចំរើន អះអាងថា ខ្លួនមានភាគហ៊ុន ៥០% ប៉ុន្តែកូនក្តីខ្លួនបានបង់ប្រាក់ចំនួន USD ៧.០០០ រួចហើយ ចំណែក [redacted] ចំរើន ទើបបង់បាន USD ៣០.០០០ ។ តើ ៥០% ប្រែមកថាស្មើគ្នាឬយ៉ាងណា ? បើប្រែថាស្មើគ្នា [redacted] ចំរើន នៅជំពាក់អង្គរវ៉ែលនដ៍ចំនួន USD ៤០.០០០ ស្មើនឹង ៣០% បន្ថែមទៀត ដែលតម្រូវឱ្យបង់ទើបមានសិទ្ធិ ៥០% ។ ថាតើជាការយោគយល់របស់កូនក្តីខ្លួនដល់កម្រិតណា ? ចំពោះសកម្មភាពរបស់ [redacted] ចំរើន ដែលកូនក្តីខ្លួនអនុញ្ញាតឱ្យគ្រប់គ្រងអាជីវកម្មដោយមិនទាន់បានដាក់ប្រាក់រហូតមកដល់ពេលនេះ ។ តើរបាយការណ៍គ្រប់គ្រង អាជីវកម្មនៅឯណា ? តាំងពីចាប់ផ្តើមគ្រប់គ្រងរហូតដល់ពេលចុះកិច្ចព្រមព្រៀងបញ្ចប់អាជីវកម្មជាមួយគ្នា តាមរយៈលិខិត ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ សម្រាប់អាជីវកម្មអង្គរវ៉ែលនដ៍ ថាតើ របាយការណ៍ចំណូលចំណាយនៅឯណាក្នុងនាមជាអ្នកគ្រប់គ្រងសណ្ឋាគារ ? ឈ្មោះអ្នកទទួលខុសត្រូវឈ្មោះលើប៉ាតង់ ឈ្មោះបង់ពន្ធ ឈ្មោះក្នុងការចុះកិច្ចសន្យាជួលសណ្ឋាគារពីម្ចាស់ដើម និងការដោះស្រាយវិវាទពាក់ព័ន្ធនឹងសណ្ឋាគារអង្គរវ៉ែលនដ៍ និងបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងអាជីវកម្មនេះ គឺឈ្មោះកូនក្តីខ្លួន ហើយកូនក្តីខ្លួនជាអ្នកដោះស្រាយពីដើមរហូតដល់ចប់ដោយឈ្មោះ [redacted] ចំរើន មិនដែលទទួលខុសត្រូវម្តងណានោះទេ ពីព្រោះឈ្មោះអាជីវកម្ម គឺឈ្មោះកូនក្តីខ្លួន ហេតុនេះពន្ធដារ ផាស៊ី ម្ចាស់សណ្ឋាគារដើម ខាងអគ្គិសនី ទឹក និងអ្នកផ្គត់ផ្គង់បន្លែ ត្រី សាច់ ជាអាទិ៍ ឱ្យសណ្ឋាគារ គឺមករកតែកូនក្តីខ្លួនឱ្យទទួលខុសត្រូវរហូតមកដល់បច្ចុប្បន្ននេះ ។ កូនក្តីខ្លួនត្រូវប្រឈមមុខគ្រប់បែបយ៉ាងនៅពេលមានបណ្តឹងប្រឆាំងនឹងអាជីវកម្មអង្គរវ៉ែលនដ៍ ដូចជាពីសំណាក់ម្ចាស់សណ្ឋាគារដើមលោក [redacted] ម៉ាលី ពាន់ព័ន្ធនឹងការជួលសណ្ឋាគារ និងផ្តាច់កិច្ចសន្យាចំពោះថ្លៃឈ្នួលសព្វគ្រប់ដែលមិនទាន់បានបង់ ដែលធ្វើឱ្យប៉ះពាល់ដល់អាជីវកម្ម មុខមាត់អាជីវកម្ម កិត្តិយសរបស់អាជីវកម្ម និងរបស់កូនក្តីខ្លួនផ្ទាល់ បណ្តាលឱ្យអាជីវកម្មខាតទៅៗ ហើយកូនក្តីខ្លួនត្រូវរ៉ាប់រងគ្រប់បែបយ៉ាង ដោយ [redacted] ចំរើន ឈរមើលមិនខ្វល់ ហើយមានមុខមកប្តឹងកូនក្តីខ្លួនទៀត នេះពិតជាទង្វើដ៏អសុទ្ធចិត្ត និងមានចេតនាបំផ្លាញអាជីវកម្ម និងបំផ្លាញកិត្តយសកូនក្តីខ្លួន ដែលតម្រូវឱ្យមានការទទួលខុសត្រូវមួយដ៏ធ្ងន់ធ្ងរតាមច្បាប់នៃទង្វើរបស់ [redacted] ចំរើន ទើបត្រឹមត្រូវ ។ ដំណើរការអាជីវកម្មសណ្ឋាគារអង្គរវ៉ែលនដ៍ស្ថិតក្រោមការគ្រប់គ្រងទូទៅរបស់ឈ្មោះ [redacted] ចំរើន ហើយអាជីវកម្មនេះបន្តខាតជាប្រចាំដែលធ្វើឱ្យកូនក្តីខ្លួនមានចម្ងល់ និងចុះមកពិនិត្យដល់ទីតាំងប្រតិបត្តិការជាក់ស្តែងទើបដឹងថា [redacted] ចំរើន គ្រប់គ្រងមិនបានល្អ [redacted] ចំរើន ជ្រើសរើសអ្នកគ្រប់គ្រងថ្មីមកចាត់ចែងអាជីវកម្មនេះ ។ [redacted] ចំរើន ក៏បានជ្រើសរើសអ្នកគ្រប់គ្រងថ្មីបាន ២ ឬ ៣ ខែ ក៏បានបញ្ឈប់អ្នកគ្រប់គ្រងថ្មីនោះ ហើយ [redacted] ចំរើន ឡើងមកចាត់ចែងការងារនេះខ្លួនឯងតែម្តង ។ ការបន្តចាត់ចែងអាជីវកម្មនេះ ក៏នៅតែមិនល្អធ្វើឱ្យអាជីវកម្មនេះនៅតែបន្តខាត និងជំពាក់បំណុលកាន់តែច្រើនទៅៗ [redacted] ចំរើន ឃើញស្ថានភាពនេះ ក៏បានស្នើសុំកូនក្តីខ្លួន



Scanned with CamScanner

ចាកចេញពីអាជីវកម្មនេះ និងមិនចង់ដឹងឮអំពីអាជីវកម្មនេះទៀតទេ ដោយប្រាប់កូនក្តីខ្លួនឱ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងបញ្ចប់ការធ្វើអាជីវកម្មរួមគ្នា ។ ប៉ុន្តែនៅពេលនោះ កូនក្តីខ្លួនមិនយល់ព្រមនោះទេ ដោយបានលើកឡើងថា បញ្ហាកំពុងកើតឡើងដែលត្រូវបន្តជួយគ្នាហេតុអ្វីរត់ចោលពាក់កណ្តាលផ្លូវបែបនេះ ។ មួយរយៈក្រោយទៀត [redacted] ចំរើន ក៏នៅតែជម្រុញកូនក្តីខ្លួនថា ឈប់រកស៊ីជាមួយគ្នាហើយ ដោយខ្លួន ([redacted] ចំរើន) សុខចិត្តបង់លុយដើម្បីចាកចេញ ។ នៅពេលនោះ កូនក្តីខ្លួនបានឆ្លើយតបវិញថា ធ្វើបែបនេះគឺទម្លាក់ការទទួលខុសត្រូវគ្រប់បែបយ៉ាងមកលើបុគ្គលតែម្នាក់ ហើយ [redacted] ចំរើន ឆ្លើយតបថា គ្មានសង្ឃឹមទេចំពោះអាជីវកម្មនេះ ។ ហេតុនេះ គប្បីបញ្ចប់ទៅដោយ [redacted] ចំរើន សុខចិត្តបង់ប្រាក់ឱ្យចំនួន USD ៥០.០០០ មកឱ្យកូនក្តីខ្លួនដើម្បីបញ្ឈប់អាជីវកម្មនេះ ។ ប៉ុន្តែសួរថា តើ [redacted] ចំរើន បានបង់ឱ្យកូនក្តីខ្លួនគ្រប់ចំនួនហើយ ឬ នៅ ? [redacted] ចំរើន ទើបបង់បាន USD ២៨.០០០ ប៉ុណ្ណោះ ហេតុអ្វី [redacted] ចំរើន ធ្វើទង្វើបែបនេះ ? ។ ចំពោះបំណុលកន្លងមក ផ្អែកតាមកិច្ចព្រមព្រៀងបញ្ចប់អាជីវកម្មនេះ ភាគីទាំងពីរត្រូវទទួលខុសត្រូវរួមគ្នា គិតចាប់ពីចាប់ផ្តើមអាជីវកម្មរហូតមុនថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ ។ ខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ គឺទី១ បញ្ចប់ការធ្វើអាជីវកម្មរួមគ្នា ចាប់ពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ តទៅ ។ ទី២ [redacted] មរកត ជាអ្នកគ្រប់គ្រងអាជីវកម្មសណ្ឋាគារអង្គរវែលនជ៍ រីឯ [redacted] ចំរើន ជាអ្នកគ្រប់គ្រងអាជីវកម្មភោជនីយដ្ឋាន មរកតស្ពាននាគ ។ ទី៣ បំណុលមុនថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ ត្រូវទទួលខុសត្រូវជាពីរចំណែក ដោយតួរលេខបំណុលសរុបត្រូវធ្វើជាឧបសម្ព័ន្ធនៃកិច្ចសន្យានេះ ទី៤ [redacted] ចំរើន ត្រូវបង់ប្រាក់ចំនួន USD ៥០.០០០ មកឱ្យ [redacted] មរកត ដោយត្រូវបង់ចំនួន USD ៣០.០០០ នៅក្នុងអំឡុងពេល ០១ សប្តាហ៍ គិតចាប់ពីថ្ងៃចុះកិច្ចសន្យា និងចំនួន USD ២០.០០០ ត្រូវបង់យ៉ាងយូរត្រឹមដំណាច់ខែកុម្ភៈ ឆ្នាំ២០១៦ ទី៥ ប្រសិនបើ [redacted] ចំរើន មិនប្រគល់ប្រាក់ទេ ចាត់ទុកថាកិច្ចសន្យានេះចាត់ទុកជាមោឃៈ ។ ហេតុនេះ [redacted] ចំរើន បានអនុវត្តកាតព្វកិច្ចមួយផ្នែក មានន័យថាកិច្ចសន្យានេះមានអានុភាពអនុវត្តតាមច្បាប់ដោយ [redacted] ចំរើន មានបំណងចាកចេញ ដោយមិនខ្វល់អ្វីទាំងអស់ ។ ចំណុចនេះ បានបង្ហាញច្បាស់ថា [redacted] ចំរើន ទុកឱ្យកូនក្តីខ្លួនទទួលខុសត្រូវគ្រប់បែបយ៉ាងនៅពេលដែលយល់ឃើញថាអាជីវកម្មបានបរាជ័យ ។ គណនីរបស់អាជីវកម្មសណ្ឋាគារ និង ភោជនីយដ្ឋានអង្គរវែលនជ៍ គឺជាគណនីរួមដោយប្រើឈ្មោះ សណ្ឋាគារអង្គរវែលនជ៍ គឺជាគណនីរួមដោយប្រើឈ្មោះសណ្ឋាគារអង្គរវែលនជ៍ ដោយអ្នកមានសិទ្ធិបញ្ជាចំណាយ គឺមានឈ្មោះពីរនាក់គឺឈ្មោះ [redacted] ចំរើន និងឈ្មោះ [redacted] មរកត ដោយប្រើលក្ខខណ្ឌបុគ្គលណាម្នាក់ក៏មានសិទ្ធិបើកប្រាក់ ឬ បញ្ជាចំណាយ មានន័យថា [redacted] ចំរើន ម្នាក់ឯង ក៏បញ្ជាចំណាយមានន័យថា [redacted] ចំរើន ម្នាក់ឯង ក៏បញ្ជាចំណាយ ឬ បើកប្រាក់ពីគណនីរួមនេះបានផងដែរ ។ [redacted] ចំរើន មានតួនាទីជានាយកចាត់ការទូទៅនៃសណ្ឋាគារ ដែលត្រូវទទួលខុសត្រូវនៅពេលមានបណ្តឹងប្រឆាំងនឹងអាជីវកម្មទើបត្រឹមត្រូវ ប៉ុន្តែ [redacted] ចំរើន មិនខ្វល់នោះទេ ។ រាល់ការចំណាយនៅក្នុងសណ្ឋាគារគឺ [redacted] ចំរើន មានសិទ្ធិបញ្ជាទាំងអស់ ដូចជា ការថែទាំជណ្តើរសណ្ឋាគារ ការផ្តល់បន្ទប់ឱ្យទៅភ្ញៀវ ការទារលុយពីអ្នកនាំភ្ញៀវ ការបញ្ជាចំណាយទៅលើប្រតិបត្តិនានា និងការចេញមូលប្បទានបត្រដោយប្រើគណនីរួមនៃអាជីវកម្មសណ្ឋាគារជាអាទិ៍ ។ [redacted] ចំរើន បានខ្ចីលុយជាច្រើនពីម្ចាស់បំណុល ដូចជា ធនាគារជាអាទិ៍ ដោយបញ្ជាក់ថា យកមកគាំទ្រអាជីវកម្មសណ្ឋាគារអង្គរវែលនជ៍ ថាតើលុយនោះបានដាក់បញ្ចូលក្នុងគណនីរបស់អង្គរវែលនជ៍ ឬទេ ? ចំនួនប៉ុន្មាន ? ពេលណា ? តើ [redacted] ចំរើន ខ្ចីប្រាក់នោះយកទៅធ្វើសកម្មភាពអ្វីពិតប្រាកដ ? ហេតុអ្វីប្រើអាជីវកម្មអង្គរវែលនជ៍ ធ្វើជាមូលដ្ឋាននៃការខ្ចី និងសងរំលោះទៅវិញ ដោយប្រើប្រាក់ចំណេញរបស់អង្គរវែលនជ៍បានធ្វើទង្វើមិនគប្បីជាច្រើនចំពោះអាជីវកម្មអង្គរវែលនជ៍ ដោយកូនក្តីខ្លួនមិនទាន់ដេញដោលបែរជាមកចោទប្រកាន់កូនក្តីខ្លួនដោយអសុទ្ធចិត្តបែបនេះទៅវិញ ។ នៅក្នុងដំណើរការអាជីវកម្មសណ្ឋាគារអង្គរវែលនជ៍គឺបានខ្ចីប្រាក់មួយចំនួនពីម្ចាស់បំណុល ហើយម្ចាស់បំណុលយល់ព្រមឱ្យខ្ចីដោយមិនឃើញអាជីវ



Scanned with CamScanner

កម្មអង្គរវ៉ែលនជ៍ ហើយប្រាក់ចំណូលពីអាជីវកម្មនេះ យកទៅសងរំលោះបំណុលសម្រាប់ម្ចាស់បំណុលជាដំណាក់កាលបន្តបន្ទាប់រហូតដាច់ឥណទានមួយ បន្ទាប់មកបន្តឥណទានមួយទៀតជាអាទិ៍ ។ ប៉ុន្តែពេលខ្ចីប្រាក់ពីធនាគារជាអាទិ៍ ដើម្បីគាំទ្រអាជីវកម្មនេះ ថាតើប្រាក់ទាំងនោះ [redacted] ចំរើន បានយកមកគាំទ្រអាជីវកម្មនេះទាំងមូល ឬទេ ? ថាតើបានបញ្ចូលមកគណនីអាជីវកម្មសណ្ឋាគារអង្គរ វ៉ែលនជ៍ ឬទេ ? គឺនៅតែជាចម្ងល់សម្រាប់កូនក្តីខ្លួន ចាប់តាំងពីពេលនោះរហូតដល់បច្ចុប្បន្នដោយសារគ្មានបញ្ជីចំណូល ចំណាយ និងបញ្ជីអាជីវកម្មត្រូវបានផ្តល់មកឱ្យកូនក្តីខ្លួននោះទេ ខណៈពេលដែលទេព ចំរើន មានតួនាទីជានាយកគ្រប់ គ្រងទូទៅរបស់សណ្ឋាគារ ។ ជារួម ការចោទប្រកាន់របស់តំណាងអយ្យការមិនទាន់មានភាពច្បាស់លាស់លើសពីវិមតិសង្ស័យនោះទេ។ ទី១ គណនីនៃអាជីវកម្មសណ្ឋាគារនេះជាគណនីរួមរវាងឈ្មោះ [redacted] មរកត និងឈ្មោះ [redacted] ចំរើន ហើយបុគ្គលណាម្នាក់ក្នុងចំណោមអ្នកទាំងពីរអាចដកប្រាក់ ឬ បញ្ជាចំណាយបានដូចគ្នា ។ ទី២ ការបង្វែរសាច់ប្រាក់នៃអាជីវកម្មនេះពីគណនីរួមដើម្បីទៅបម្រើប្រយោជន៍ផ្ទាល់ខ្លួនដូចជា ទិញខុនដូរថយន្ត ឬ បើកប្រាក់ទៅឱ្យបុគ្គលមិនពាក់ព័ន្ធនឹងអាជីវកម្ម ជាអាទិ៍ ជាការអះអាងដោយគ្មានភស្តុតាង ។ ទី៣ អ្នកបញ្ជាចំណាយ និងគ្រប់គ្រងអាជីវកម្មសណ្ឋាគារ គឺ [redacted] ចំរើន មិនមែន [redacted] មរកត នោះទេ ។ ទី៤ [redacted] ចំរើន បានបំផ្លាញអាជីវកម្មនេះស្ទើរស្ទើសូន្យ ហើយរត់យករួចខ្លួនសុខចិត្តចំណាយប្រាក់ USD ៥០.០០០ និងរុញការទទួលខុសត្រូវគ្រប់បែបយ៉ាងឱ្យមកកូនក្តីខ្លួន ។ តើនេះជាទង្វើរបស់ដៃគូអាជីវកម្ម ឬយ៉ាងណា ? ប៉ុន្តែលុយ USD ៥០.០០០ មិនទាន់បានបង់ផងដែរ ហើយថ្លៃចូលភាគហ៊ុននៃការធ្វើអាជីវកម្មសណ្ឋាគារនេះក៏មិនបង់គ្រប់ចំនួនផងដែរ ។ ការអះអាង និងចោទប្រកាន់របស់ [redacted] ចំរើន ឬតំណាងអយ្យការខាងលើនេះគឺគ្មានមូលដ្ឋានផ្លូវច្បាប់ និងភស្តុតាងឱ្យលើសពីវិមតិសង្ស័យដែលអាចឱ្យកំណត់អំពីតម្រុយនៃពិរុទ្ធភាពនៃបទល្មើស រំលោភលើទំនុកចិត្ត នោះទេ បើផ្អែកលើភស្តុតាងក្នុងសំណុំរឿង ឬ របាយការណ៍របស់ធនាគារ ANZ Royal ជាប្រវត្តិនៃប្រតិបត្តិការចេញចូលគណនីសម្រាប់ដំណើរការអាជីវកម្ម ដោយគ្មានចំណុចត្រង់ណាអាចបញ្ជាក់អំពីការបង្វែរទ្រព្យនៃអាជីវកម្មរួមទៅបម្រើប្រយោជន៍ផ្ទាល់ខ្លួនរបស់កូនក្តីខ្លួននោះទេ ។ [redacted] ចំរើន មិនដែរចេញមុខមកទទួលខុសត្រូវ ឬដោះស្រាយនៅពេលមានបណ្តឹងប្រឆាំងនឹងអាជីវកម្មសណ្ឋាគារម្តងណានោះទេ ដូចជា ម្ចាស់ដីដើម (ភតិបតី) ដែលបានជួលសណ្ឋាគារមកឱ្យធ្វើអាជីវកម្ម នៅពេលអត់បង់ប្រាក់ឈ្នួលទាន់ពេលកំណត់ ហើយម្ចាស់ដើមទាមទារ និងបានប្តឹងទៅតុលាការ គឺកូនក្តីខ្លួនជាអ្នកចេញមុខដោះស្រាយ និងរឿងផ្សេងៗទៀតផងដែរ ដូចជាទឹកភ្លើង ពន្ធ និងដៃគូអាជីវកម្មដទៃផ្សេងទៀត ។ គ្មានតម្រុយពិរុទ្ធភាពចំពោះបទល្មើសរំលោភលើទំនុកចិត្តឱ្យលើសពីវិមតិសង្ស័យចំពោះកូនក្តីខ្លួននោះទេ ។ សូមតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទពីព្រោះជនជាប់ចោទគ្មានកំហុសនោះទេ (មាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) និងបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការលើកូនក្តីខ្លួន (មាត្រា ៣៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ) ។

ក្រោយពីសួរដេញដោលក្នុងអង្គសវនាការ

ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ



Scanned with CamScanner

ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាលើសំណុំរឿងត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ លេខ ៥៥១៥ "ផ"ដជ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជូនជនជាប់ចោទ ឈ្មោះ [redacted] **មរកត** ទៅជំនុំជម្រះពី បទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅខេត្តសៀមរាប ចាប់ពីឆ្នាំ២០០៩ ដល់ ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ជនជាប់ចោទបានប្រើប្រាស់ប្រាក់ដែលទទួលបានពីអាជីវកម្មរួមគ្នាដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន ។ ប៉ុន្តែជនជាប់ចោទនៅតែបដិសេធថា ជនជាប់ចោទមិនបានប្រព្រឹត្តអំពើគៃបំបាត់នេះទេ ។

-តាមរបាយការណ៍ប្រតិបត្តិសាច់ប្រាក់ក្នុងគណនីលេខ ៨៤៣១៥៥ ដែលមានម្ចាស់គណនីរួមឈ្មោះ [redacted] BUNNEANG និងឈ្មោះ [redacted] MOROKOT ឃើញថា មានការដាក់សាច់ប្រាក់ដែលបានមកពីចំណូលរបស់ក្រុមហ៊ុន (ចំណូលទទួលបានពីក្រុមហ៊ុនទេសចរណ៍) និងមានការផ្ទេរប្រាក់ពីគណនីសណ្ឋាគារអង្គរវ៉េន ដែលមានគណនីលេខ ១៩០២៤៧០ (ANZ BANK) គណនីសណ្ឋាគារសៀមរាបថោន ដែលមានគណនីលេខ ១២៣៣២៥២ (ANZ BANK) ចូលទៅក្នុងគណនីធនាគារផ្ទាល់ខ្លួនរបស់ឈ្មោះ [redacted] **មរកត** និងស្វាមីឈ្មោះ [redacted] **ប៊ុននាង** មែន ។

-យោងតាមដីកាសន្និដ្ឋានស្ថាពរ តាមពាក្យបណ្តឹង តាមចម្លើយរបស់ជនជាប់ចោទ និងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាងជាឯកសារនានាដែលមានក្នុងសំណុំរឿងមានភាពស៊ីសង្វាក់ក្នុងការបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] **មរកត** ពិតជាបានធ្វើសកម្មភាពគៃបំបាត់នូវប្រាក់របស់អាជីវកម្មសណ្ឋាគារអង្គរវ៉េន ប្រព្រឹត្តនៅខេត្តសៀមរាប ចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៥ ។

-ចម្លើយបដិសេធរបស់ជនជាប់ចោទគ្រាន់តែជាការឆ្លើយដោះសារមិនមានសំអាង ដើម្បីបញ្ជាក់មកតុលាការអំពីទំនាក់ទំនង និងមូលហេតុនៃការផ្ទេរប្រាក់ពីអាជីវកម្មសណ្ឋាគារអង្គរវេនទៅក្នុងគណនីរបស់ជនជាប់ចោទនោះទេ ។

-យោងតាមបញ្ញត្តិមាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌ អំពើគៃបំបាត់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ នាំអោយខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបានប្រគល់អោយបុគ្គលនោះ ហើយបុគ្គលនោះបានយល់ព្រមដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬ យកមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់ជា**អំពើរំលោភលើទំនុកចិត្ត** ។

-អំពើរបស់ជនជាប់ចោទដែលបានគៃបំបាត់ជាប្រយោជន៍ផ្ទាល់ខ្លួននូវទ្រព្យសម្បត្តិ (សាច់ប្រាក់) ដែលខ្លួនបានទទួលនូវការប្រគល់ដើម្បីប្រើប្រាស់ជាកំណត់ របស់អាជីវកម្មសណ្ឋាគារអង្គរវេន ហើយតាមរយៈអំពើនេះបានបង្កឱ្យសណ្ឋាគារ និងដើមបណ្តឹងរដ្ឋប្បវេណីទទួលរងការខូចខាតនូវផលប្រយោជន៍ ជាបទល្មើស **រំលោភលើទំនុកចិត្ត** ។

-ជនជាប់ចោទជានីតិជន នាពេលប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពដែលអាចយល់ដឹងអំពីលទ្ធផលតាមផ្លូវច្បាប់ចំពោះអំពើរបស់ខ្លួនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការមានភាពសមហេតុផលគប្បីតុលាការលើកយកមកពិចារណា ។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មិនមានសំអាងគ្រប់គ្រាន់ មិនអាចឱ្យតុលាការជឿជាក់បានឡើយ ។

-មានពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទ ឈ្មោះ [redacted] **មរកត** ភេទស្រី អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ ពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅខេត្តសៀមរាប ចាប់ពីឆ្នាំ២០០៩-២០១៥ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីបានទាមទារសំណងប្រាក់ដែលជនជាប់ចោទបានគៃបំបាត់ចំនួន USD ២២៦.៥៨៦ ប៉ុន្តែពុំទាន់មានការបញ្ជាក់ច្បាស់លាស់នូវឡើយទៅលើសាច់ប្រាក់ដែលបានគៃបំបាត់នោះ ដោយហេតុថា ប្រតិបត្តិការណ៍មួយចំនួនមិនបានបញ្ជាក់ថា ជាប្រតិបត្តិការពាក់ព័ន្ធទៅនឹងអាជីវកម្មសណ្ឋាគារនោះទេ ។ ហេតុដូចនេះ ដើម្បីធានាភាពត្រឹមត្រូវនៃសំណងរដ្ឋប្បវេណី តុលាការយល់ឃើញថា គប្បីទុកសិទ្ធិជូនដើមបណ្តឹងរដ្ឋប្បវេណីទាមទារអំពីសំណងទៅលើប្រាក់ដែលបានបាត់បង់តាមនីតិវិធីរដ្ឋប្បវេណី ហើយតុលាការនឹងពិចារណាសម្រេចតែទៅលើសំណងជម្ងឺចិត្តប៉ុណ្ណោះ ។ ក្នុងស្ថានភាពដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់ទៅលើការទាមទារ អំពីជម្ងឺចិត្តនេះ តុលាការនឹងពិចារណាអំពីចំនួននៃសំណងនេះតាមការជាក់ស្តែង ។

## <u>ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី</u>

**១-ផ្តន្ទាទោស** ឈ្មោះ [redacted] **មរកត** ភេទស្រី ដែលមានអត្តសញ្ញាណខាងលើ ដាក់ពន្ធនាគារកំណត់ ០១ (**មួយ**) **ឆ្នាំ** ពីបទ ***រំលោភលើទំនុកចិត្ត*** ប្រព្រឹត្តនៅខេត្តសៀមរាប ចាប់ពីឆ្នាំ២០០៩-២០១៥ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យឈ្មោះ [redacted] **មរកត** សងសំណងជម្ងឺចិត្តចំនួន ៨.០០០.០០០ **(ប្រាំបីលាន) រៀល** ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ចំរើន** ។

សាលក្រមនេះបញ្ចប់ការជំនុំជម្រះនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **មរកត** និង ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ចំរើន** ប្រកាសជាសាធារណៈ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ទុកសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ហត្ថលេខា និងត្រាក្រឡាបញ្ជី

[redacted]

ហត្ថលេខា និងត្រាចៅក្រម

[redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃសុក្រ ៧ កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃសុក្រ ៧ កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩

**ចៅក្រម**

[redacted]



Scanned with CamScanner